# ព្រះរាជជីវប្រវត្តិសង្ខេប




## ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ សម្រាប់ត្រៀមប្រលងសញ្ញាបត្រទុតិយភូមិ ឆ្នាំ២០១៨

ដោយនវកវី មនោរថ យ៉ូន តារា

# អារម្ភកថា

ខ្ញុំព្រះកូណាបានប្រមូលរៀបរៀងធ្វើជានេះឡើង ក៏ព្រោះបានទឹងឃើញស្នាដៃរបស់ព្រះករុណា ព្រះបាទសម្ដេចនរោត្តមសីហនុកសាងនូវសមិទ្ធិផលជាច្រើនមានដូចជាសប្បកម្មផ្សេងៗដែលសម្ដេចបានកសាងឡើង និងការដឹងនាំដ៏ឈ្លាសវៃរបស់ព្រះអង្គធ្វើឲ្យប្រជានុរាស្ត្រប្រកបដោយធម៌ ធ្វើឲ្យប្រជាជនមាននូវជំនឿទុកចិត្តលើព្រះអង្គ ។

*ស្រុកកណ្ដាលស្ទឹងថ្ងៃអាទិត្យ ទី២១ ខែកញ្ញា ឆ្នាំ២០១៤*

**នវកថ មនោរថ យ៉ុន តារា**

# ព្រះរាជជីវប្រវត្តិសង្ខេប

F ព្រះករុណាសម្តេចព្រះនរោត្តមសីហនុ ។

ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ព្រះមហាក្សត្រព្រះរាជបិតាឯករាជបូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះអង្គប្រសូត្រនៅថ្ងៃអង្គារ ១១កើត ខែកត្តិក ឆ្នាំច ចត្វាស័ក ពុទ្ធស័ករាជ ២៤៦៦ ត្រូវនឹងថ្ងៃទី៣១ ខែតុលា ឆ្នាំ ១៩២២ នៅរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា ។

ចាប់ពីឆ្នាំ១៩៣0 ដល់ ១៩៤0 ព្រះអង្គបានចូលសិក្សានៅសាលាបឋមសិក្សា(FRANCOISBAUDOIN) និងវិទ្យាល័យព្រះស៊ីសុវត្ថ រាជធានីភ្នំពេញ ។ បន្ទាប់មកព្រះអង្គបានបន្តការសិក្សានៅវិទ្យាល័យបារាំងសាសលូឡបា(CHASSCLOUPLAUBAT) នៅព្រៃនគរ(វៀតណាមខាងត្បូង) លុះដល់ខែមេសា ឆ្នាំ១៩៤១ ក្រុមប្រឹក្សាព្រះរាជបល្ល័ង្កបានជ្រើស

តាំងនិងថ្វាយព្រះរាជឋានៈ ព្រះអង្គជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជានៅរាជធានីភ្នំពេញ ។ ព្រះអង្គឡើងគ្រងរាជសម្បត្តិថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៤១ ។ នៅឆ្នាំ១៩៤៦ ព្រះអង្គបានយាងទស្សនកិច្ចលើកដំបូង នៅប្រទេសបារាំង តាមការអញ្ជើញរបស់លោកប្រធានាធិបតី (FELIXGOUIN) និងបានជួបលោកឧត្តមសេនីសាលជីហ្គោ (CHARLESDE GAULLE) នៅ (COLOBEY) ។ នៅឆ្នាំ១៩៤៦និង១៩៤៨ ព្រះអង្គបានបន្តការសិក្សាជាន់ខ្ពស់ នៅសាលាអនិវត្តទ័ពសេះ និងកងទ័ពរថពាសដែកនៅ(SAUMUR)ប្រទេសបារាំង ។

ក្នុងឆ្នាំ១៩៤៧ព្រះបាទសម្តេចព្រះនរោត្តមសីហនុព្រះអង្គមានមហាជោជ័យក្នុងការទាមទារឲ្យរាជាណាចក្រថៃឡង់សងមកកម្ពុជាវិញដាច់ខាតនៅខេត្តខ្មែរដែលក្នុងពេលមានចម្បាំងលោកលើកទីពីរ ថៃឡង់បានយកពីកម្ពុជាទៅគឺ៖ ខេត្តបាត់ដំបង សៀមរាប ស្ទឹងត្រែង កំពង់ធំ ។ ឆ្នាំ១៩៤៩ ព្រះ

ករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុបានទាមទារឲ្យប្រទេសបារាំងបញ្ចប់នៅសន្ធិសញ្ញាអាណាព្យាបាល ដែលបានចុះព្រះហ័ស្ថលេខានៅឆ្នាំ១៨៦៣និងឆ្នាំ១៨៨៤ ។ នៅឆ្នាំ១៩៤៩ដដែលព្រះអង្គបានឡាយព្រះហ័ស្ថលេខាលើសន្ធិសញ្ញាឯករាជ្យដែលប្រទេលបារាំងព្រមទទួលស្គាល់តាមផ្លូវច្បាប់នៅឯករាជ្យរបស់ព្រះរាជាណាចក្រកម្ពុជា ។ សន្ធិសញ្ញាឆ្នាំ១៩៤៩នេះ លុបចោលនូវសន្ធិសញ្ញាអាណាព្យាបាលឆ្នាំ១៨៦៣និង១៨៨៤ ។ ពីឆ្នាំ១៩៥២ដល់ឆ្នាំ១៩៥៣ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុព្រះអង្គបានយាងបំពេញព្រះរាជបូជនីយកិច្ចទាមទារបេតិកភ័ណ្ឌឯករាជ្យ១០០គីឡូម៉ែត្រជួយជាតិមាតុភូមិ ។

នៅថ្ងៃទី៩ខែវិច្ឆិកាឆ្នាំ១៩៥៣ ដោយស្នាមព្រះហ័ស្ថដ៏ឧត្តុង្គឧត្តមរបស់ព្រះអង្គ ព្រះរាជាណាចក្រកម្ពុជាបានទទួលឯករាជ្យទាំងស្រង់ពីសាធារណរដ្ឋបារាំង ។ ប្រជារាស្ត្រកម្ពុជាទូ

ទាំងប្រទេស សូមថ្វាយព្រះកិត្តិនាមព្រះអង្គជា "ព្រះមហាវីរៈបុរសជាតិ ព្រះបិតាឯករាជ្យជាតិ" ។ ឆ្នាំ១៩៥៤ព្រះអង្គបានបញ្ជូលរាជហ្សានៈប្រតិភូជាតំណាងរបស់ព្រះអង្គទៅចូលរួមនៅក្នុងសន្និសិតអន្តរជាតិស្តីពីបញ្ហាឥណ្ឌូចិនទីក្រុងសឺណែវ(GENEYE) ដែលមានប្រទេសកម្ពុជាចូលរួមក្នុងឋានៈជារដ្ឋឯករាជ្យឯកភាពជាតិ ។

នៅថ្ងៃទី៣ខែមិនា ឆ្នាំ១៩៥៥ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុព្រះអង្គបានដាក់រាជ្យថ្វាយព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសុរាម្រឹតជាព្រះរាជបិតា ។ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសុរាម្រឹតព្រះអង្គបានប្រទានចំពោះព្រះករុណាព្រះបាទសម្តេចនរោត្តមសីហនុនូវព្រះបរមងារជា "ព្រះឧបយុវរាជនៃព្រះរាជាណាចក្រកម្ពុជា" ។ ថ្ងៃ២៣ខែមិនាឆ្នាំ១៩៥៥ព្រះករុណាព្រះបាតព្រះនរោត្តមសីហនុព្រះ

បានបង្កើតចលនាសង្គមរាស្ត្រនិយម ដែលមានគណបក្សជាច្រើនចូលរួមក្នុងចលនានេះ ។

ពីថ្ងៃទី១៨ ដល់ថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៥៥ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ព្រះអង្គបានយាងចូលរួមក្នុងសន្និសិតកំពូលអាព្រិច ។

–អាស៊ីលើកទី១ នៅទីក្រុងបាន់ដុង(ប្រទេសឥណ្ឌូនេស៊ី) ហើយនៅទីនោះព្រះអង្គបានប្រកាសពីនយោបាយអព្យាក្រឹតក្នុងឯករាជ្យទាំងស្រង់និងសន្តិសហវិជ្ជមាន នៃព្រះរាជាណាចក្រកម្ពុជាជាមួយបណ្តាប្រទេសទាំងអស់ដោយមិនគិតពីមនោគមន៍វិជ្ជាឡើយ ។ ព្រះអង្គបានជួបជាលើដំបូងជាមួយនិងលោកហ្សាវ៉ាហារលាស់នេរុ(GAWAHARLALNEHRU) និយករដ្ឋមន្ត្រីឥណ្ឌា លោកហ្គាម៉ាល់អាប់ដែលណាស៊ែរ្យ (GAMALABDELNASSEL) ប្រធានាធិបតីសាធារណរដ្ឋអារាប់រួម លោកអាម៉េតស៊ូការណូ(AHMED SUKABRNO)

ប្រធានាធិបតីឥណ្ឌូនេស៊ីលោកជូអេនឡាយ(ZAHHOUENLAI)និយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិកចិន ។

ថ្ងៃទី១១ខែកញ្ញាឆ្នាំ១៩៥៥ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ព្រះអង្គបានទទួលមហាជោគជ័យក្នុងការបោះឆ្នោតសភាជាតិ ដោយបានទទួលគាំទ្រពីប្រជារាស្ត្រខ្មែរច្រើនលើសលុប ។ ព្រះអង្គបានទទួលព្រះរាជឋានៈជានិយករដ្ឋមន្ត្រីហើយក្នុងព្រះរាជឋានៈជាមុខ នៃប្រជារាស្ត្រខ្មែរព្រះអង្គបានបំពេញព្រះរាជកិច្ចដឹកនាំដើម្បីអភិវឌ្ឍន៍ព្រះរាជាណាចក្រកម្ពុជាជាទូទៅនៅក្នុងគ្រប់វិស័យនៃការកសាងជាតិរបស់ព្រះអង្គជាពិសេសការលើកស្ទួយនារីឲ្យមានសិទ្ធិស្មើរភាពនឹងបុរសក្នុងការងារ ។

ថ្ងៃទី១៤ ខែកញ្ញាឆ្នាំ១៩៥៥ក្រោមព្រះរាជកិច្ចដឹងនាំរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុប្រទេសកម្ពុជាបានចូលជាសមាជិកនៃអង្គការសហប្រជាជាតិ ។

នៅឆ្នាំ១៩៥៦ នៅប្រីយ៉ូនី(BRIONI)នៃសាធារណរដ្ឋសហព័ន្ធសង្គមនិយមយូហ្គោស្លាវីព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុព្រះអង្គបានក្លាយជាបិតាស្ថាបនិកទី៥ចលនាមិនចូលបក្សសម្ព័ន្ធបន្ទាប់ពីអ្នកផ្តួចផ្តើមគំនិតសំខាន់៤រូបទៀត៖

-លោកហ្សូស៊ីបប្រូសទីតូ(JOISIPBROZTITO) ប្រធានាធិបតីយូហ្គោស្លាវី លោកហ្សាវ៉ាហាលាស់នេរុ(JAWAHARLALNEHRU) នាយករដ្ឋមន្ត្រីឥណ្ឌាលោកម៉េតស៊ូកាណូ(AHMEDSUKARNO) ប្រធានាធិបតីឥណ្ឌូនេស៊ីនិងលោកហ្គាលម៉ាល់អាប់ដែលណាស៊ែរ(JAMALABDELNASSER) ប្រធានាធិបតីសាធារណរដ្ឋអារ៉ាប់រួម ។

នៅខែកុម្ភៈឆ្នាំ១៩៥៦ ព្រះករុណាព្រះបាទសម្តេចព្រនរោត្តមសីហនុក្នុងព្រះរាជឋានៈ ជានាយករដ្ឋមន្ត្រីព្រះបានយាងទៅបំពេញទស្សនៈកិច្ចជាផ្លូវរដ្ឋនៅសាធារណរដ្ឋប្រជាមានិក

ចិន និង បានជួបជាមួយថ្នាក់ដឹងនាំចិនជាច្រើនរូបមានឯក-ឧត្តមលោកប្រធានម៉ៅសេទុង(MAOTSE-TUNG)ជាដើម ។ ព្រះអង្គបានឡាយព្រះហ័ស្ថលេខាលើសេចក្តីប្រកាសរួមស្តីពីមិត្តភាពកម្ពុជា-ចិន ។

នៅឆ្នាំ១៩៦០ ព្រះករុណាសម្តេចព្រះនរោត្តមសុរាម្រឹតទ្រង់សោយទីវង្គត់ពេលនោះព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុត្រូវបានសមាជិកសភាខ្មែរបានសម្រេចជាឯ-កច្ឆ័ន ជ្រើសតាំងព្រះអង្គជាប្រមុខរដ្ឋនៃព្រះរាជាណាចក្រកម្ពុ-ជា ។ ក្នុងព្រះឋានៈនេះព្រះអង្គបានបន្តការដឹងនាំប្រជារាស្ត្រខ្មែរ ។

ក្នុងព្រះរាជកិច្ចកសាងជាតិមាតុភូមិយ៉ាងសកម្មជាទីបំផុត ។

ខែកញ្ញា ឆ្នាំ១៩៦០ នៅមហាសន្និបាតអង្គការសហប្រជាជាតិ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ព្រះអង្គ

បានលើកឡើងនូវផែនការបង្កើតនៅអាស៊ីអាគ្នេយ៍ជាតំបន់អ-ព្យាក្រឹតរវាងប្រលុកមហាអំណាចទាំងពីរ ។ នៅខែឧសភាឆ្នាំ ១៩៦១ តាមព្រះរាជតម្រិះផ្តួចផ្តើមរបស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តមសីហនុ សន្និសិតអន្តរជាតិមួយត្រូវបាន បង្កើតឡើងនៅទីក្រុងសឺណេវ(GENEYE) ដើម្បីដោះស្រាយ ទំនាស់រវាងភាគីទាំងបីនៅប្រទេសឡាវ ។ ចាប់ពីខែឧសភា ឆ្នាំ១៩៦១ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ព្រះអង្គបានបំពេញព្រះរាជបេសកម្មនយោបាយការទូត ដើម្បី ទាមទារប្រសាទព្រះវិហារជាសម្បត្តិវប្បធម៌បេតិកភ័ណ្ឌជាតិ ខ្មែរមកវិញពីប្រទេសថៃ ដោយតុលាក្រុងឡាអេ(LAHAYE) បានសម្រេចប្រគល់មកព្រះរាជាណាចក្រកម្ពុជាវិញ នៅថ្ងៃទី ១៥ ខែមិថុនាឆ្នាំ១៩៦៧ ។

នៅខែវិច្ឆិកា ឆ្នាំ១៩៦១ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តមព្រះអង្គបានយាងចូលរួមក្នុងសន្និសិតកំពូលលើកទី១

នៃចលនាមិនបានចូលបក្សសម្ពន្ធនៅបែលក្រាដ(BELCIRA DE)នៃប្រទេសយូហ្គោស្លាវីដែលមាន ២៩ប្រទេសចូលរួម ។

នៅទីនោះព្រះបានថ្កោលទោស ចំពោះអំពើរបស់ពួកអាណានិគមន៍ចក្រព័ន្ធនិយមនិងការប្រកាន់ពូជសាសន៍ ។

នៅខែមិថុនាឆ្នាំ១៩៦៤ លោកឧត្តមសេនីយ៍សាដឺហ្គោល (CHARLESDEGAYLLE) ប្រធានាធិបតីនៃសាធារណរដ្ឋបារាំងបានរាប់ចំបដិសណ្ឋារកិច្ចឱឡារិក ថ្វាយព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុនៅទីក្រុងបារិស ។ លោកប្រធានាធិបតីបានទទួលដោយស្មោះសរនៅសំណើររបស់ភាគីកម្ពុជាស្តីពីការទទួលស្គាល់អព្យាក្រឹត នៃព្រះរាជាណាចក្រកម្ពុជា ។

នៅចុងខែសីហានិងដើមខែកញ្ញា ឆ្នាំ១៩៦៦ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុបានរាប់ចំបដិសណ្ឋារកិច្ច

ទទួលជាឱឡារិកលោកឧត្តមសេនីយ៍សាដឺហ្គោល(CHARLE SDEGAYLLE)ប្រធានាធិបតីនៃសាធារណរដ្ឋបារាំងដែលបានមកបំពេញទស្សនៈកិច្ចជាផ្លូវរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា។

ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ១៩៦៦ នៅក្នុងសន្ទរកថាដោយថ្លែងទៅពហុកីឡាស្ថានជាតិអូឡាំពិចភ្នំពេញលោកប្រធានា-ធិបតីបានគាំទ្រព្រះរាជាណាចក្រកម្ពុជា ដែលការពារឯករាជ្យបូរណភាពទឹកដីសន្តិភាពនៃខ្លួន។

ពីថ្ងៃទី ២៦ ខែ វិច្ឆិកា ដល់ថ្ងៃទី៦ខែធ្នូឆ្នាំ១៩៦៦ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ បានយាងជាព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងឱកាសព្រះរាជវិធីបើកនិងបិទការប្រកួតកីឡាGANEFOអាស៊ីលើកទី១។

ក្រោយព្រះរាជកិច្ចដឹកនាំរបស់សម្តេចព្រះនរោត្តមសីហនុក្នុងសម័យសង្គមរាស្ត្រនិយមដែលប្រជារាស្ត្រខ្មែរ បានថ្វាយ

ព្រះនាមព្រះអង្គថាជាព្រះបិតាឯករាជ្យជាតិព្រះបិតាសិក្សាធិ-កាជាតិជាបិតាសុខាភិបាលជាតិព្រះបិតាកីឡាជាតិព្រះបិតាស្ថាបនាជាតិសមិទ្ធិផលជាច្រើន បានត្រូវកសាងឡើងនិងប្រារព្ធព្រះរាជពិធីសម្ពោធជាបន្តបន្ទាប់សម្រាប់ប្រជារាស្ត្រប្រើប្រាស់នៅតាមបណ្តាលខេត្ត-ក្រុងនានាជាពិសេសមានសមិទ្ធិផលធំៗនានាដូចជា៖

- វិមានឯករាជ្យ
- វិមានរដ្ឋចំការមន
- ចំណតអាកាសយានឋានបូជិនតុង
- ចំណតអាកាសយានឋានសៀមរាប
- ចំណតអាកាសយានឋានបែកចានខេត្តបាត់ដំបង
- ផ្លូវជាតិលេខ៤ ភ្នំពេញ-ក្រុងព្រះសីហនុ
- ផ្លូវដែកក្រុងភ្នំពេញ-ក្រុងព្រះសីហនុ
- កំពុងផែរអន្តរជាតិក្រុងព្រះសីហនុ

- សណ្ឋាគារ “ឯករាជ្យ”ក្រុងព្រះសីហនុ
- សាលមហោស្រព “ព្រះសុរាម្រឹត”ភ្នំពេញ
- សន្និសិត “ចតុមុខ”
- ពហុកីឡាស្ថានជាតិអូឡាំពិចភ្នំពេញ
- ស្ពានព្រះមុនីវង្សទី២
- ស្ពាន “សង្គមរាស្រ្តនិយម” សង្កាត់ទន្លេសាប
- សាកលវិទ្យាល័យ “សង្គមរាស្រ្តនិយម”ភ្នំពេញ
- សាកលវិទ្យាល័យភូមិន្ទបច្ចេកទេស
- មហាវិទ្យានីតិសាស្រ្តនិងវិទ្យាសាស្រ្តសេដ្ឋកិច្ច
- មហាវិទ្យាល័យគរុកោសល្យ
- ពុទ្ធាសាកលវិទ្យាល័យព្រះសីហនុរាជ
- មហាវិទ្យាល័យសិល្បៈស្ថាបនា
- មហាវិទ្យាល័យសិល្បៈនិងមុខរបរ
- សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

- សាកលវិទ្យាល័យភូមិន្ទសេដ្ឋសាស្ត្រ
- សាកលវិទ្យាល័យភូមិន្ទកំពង់ចាម
- សាកលវិទ្យាល័យភូមិន្ទបាត់ដំបង
- សាកលវិទ្យាល័យភូមិន្ទតាកែវ-កំពត
- រោងចក្រភាគយន្តរដ្ឋ
- ស្ថានីយ៍ទូរទស្សន៍ខេមរៈភូមិន្ទ
- មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត
- រោងចក្រប្រេងកាតក្រុងព្រះសីហនុ
- រោងចក្រ “ព្រះនរោត្តម” តំឡើងត្រាក់ទ័រនិងរថយន្តធំក្រុងព្រះសីហនុ
- រោងចក្រស្ករសកំពង់ត្រាំខេត្តកំពង់ស្ពឺ
- រោងចក្រវាយនភ័ណ្ឌខេត្តកំពង់ចាម
- រោងចក្រវាយនភ័ណ្ឌខេត្តបាត់ដំបង
- រោងចក្របាវក្រចៅដូនទាវខេត្តបាត់ដំបង

- រោងចក្រស៊ីម៉ង់ចក្រីទីញខេត្តកំពត
- រោងចក្រកែងជើងឯករាជធានីភ្នំពេញ
- រោងចក្រក្តារបន្ទះដីឥដ្ឋខេត្តកណ្តាល
- រោងចក្រក្រដាស់ឆ្លូវខេត្តក្រចេះ
- រោងចក្រជីហ្វូសស្វាតទូកមាសខេត្តកំពត
- រោងចក្រកង់ឡានតាខ្មៅខេត្តកណ្តាល
- រោងចក្រត្រីខប្រអប់ខេត្តកោះកុង
- រោងចក្រផលិតជ័រកៅស៊ូជប់ខេត្តកំពង់ចាម
- រោងចក្រវារីអគ្គីសនីយ៍ខេត្តកំពង់ស្ពឺ
- និងសមិទ្ធផលនានាជាច្រើនទៀត នៅតាមបណ្តាលស្រុក ខេត្ត ក្រុង ដូចជា សាលារៀន មន្ទីរពេទ្យ ទំនប់ទឹង ស្រះទឹក ប្រឡាយ ផ្លូវថ្នល់ ស្ពានជាដើម -ល- ។

-នៅថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៧០ ក្នុងពេលដែលព្រះអង្គកំពុងបំពេញព្រះរាជទស្សនៈកិច្ចជាផ្លូវការនៅសហភាពសូវៀ

ត ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ត្រូវបានទទួលរងគ្រោះដោយរដ្ឋប្រហារមិនស្របច្បាប់មួយនៅភ្នំពេញ គឺជារដ្ឋប្រហារយោធាដែលមានលន់នល់ជាមេក្លោង ។ សាធារណរដ្ឋរបស់លន់នល់ ត្រូវបានបង្កើតឡើងនៅខែតុលាឆ្នាំ១៩៧០ ។

នៅថ្ងៃទី២៣ខែមិនាឆ្នាំ១៩៧០ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ព្រះអង្គជាព្រះប្រធានចលនាតស៊ូកម្ពុជា «រណសិរ្សរួបរួមជាតិកម្ពុជា» (FUNC) ព្រមជាមួយនោះក៏មានបង្កើតនូវរាជរដ្ឋាភិបាលរួបរួមកម្ពុជា(GRUNK) ។

នៅខែមេសាឆ្នាំ១៩៧០ នៅកង់តង់(សាធារណរដ្ឋប្រជាមិនិកចិន) ព្រះអង្គជាអ្នកផ្តួចផ្តើមនៃសន្និសិតកំពូលរបស់ប្រជាជនឥណ្ឌូចិន ដែលនៅក្នុងនោះមានការចូលរួមដោយដឹងនាំពីប្រទេសកម្ពុជាពីសាធារណរដ្ឋប្រជានិធិធិប្បតេយ្យវៀតណាម ដឹកនាំដោយនាយករដ្ឋមន្ត្រីផាំចាន់ខុង(PHAMVANOONG)

ពីរណសិរ្សជាតិរំដោះវៀតណាមខាងត្បូងដឹកនាំដោយលោកង្វៀងហ៊ីវថ(NGUVENHWWTHO) និងពីណេវឡាវហាក់សាត(NERLARHAKSAT) ដឹកនាំដោយព្រះអង្គម្ចាស់ប្រធានសុផានុវង្ស (SOUTHANOUYONG) ។ ភាគីសាធារណរដ្ឋប្រជាធិធិបតេយ្យវៀតណាម-រណសិរ្សជាតិរំដោះវៀតណាមខាងត្បូងនិងភាគីណេវឡាវហាក់សាត(NEO LAOHAKSAT) បានប្រកាសជាឱឡារិកថាប្រទេសរបស់ខ្លួនទទួលស្គាល់និងគោរពជាដរាប បូរណភាពទឹកដីក្នុងព្រំដែនបច្ចុប្បន្នកម្ពុជា ។

ថ្ងៃទី១៧ខែមេសាឆ្នាំ១៩៧៥ កងទ័ពប្រជាជនរំដោះជាតិនៃរណសិរ្សរួបរួមជាតិកម្ពុជា (FUNC) ដណ្ដើមបានជ័យជំនះទាំងស្រុងនៅកម្ពុជា ។ “កម្ពុជាប្រជាធិបតេយ្យ” ត្រូវបានបង្កើតឡើងដែលមានព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុជាព្រះប្រធាន ។ ប៉ុន្តែនៅខែមេសាឆ្នាំ១៩៧៦ ព្រះ

ករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុព្រះបានសប់ព្រះរាជហឫទ័យលើកលែងមុខងារជាប្រធាននៃកម្ពុជាប្រជាធិបតេយ្យនេះ ហើយត្រូវពួកខ្មែរក្រហមឃុំឃាំងព្រះអង្គនិងសម្តេចព្រះរាជអគ្គមហេសីព្រមទាំងធ្វើគង់ព្រះរាជបុត្រាបុត្រីមួយចំនួនផង ។

នៅឆ្នាំ ១៩៨២ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុត្រូវបានជ្រើសតាំងជាប្រធានកម្ពុជាប្រជាធិបតេយ្យជាលើកទី២ ។

ពីឆ្នាំ ១៩៨២ដល់ ឆ្នាំ១៩៩០ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុព្រះអង្គជាប្រធាននៃចលនាតស៊ូជាតិកម្ពុជា(CNR) ។

ចាប់តាំង១៩៨៧ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុព្រះអង្គបានខិតខំអស់ពីព្រះកាយពល ដើម្បីបំរួបបំរួម

ភាគីជំលួសកម្ពុជាទាំងអស់ រិះរកដំណោះស្រាយនយោបាយសមស្របបញ្ចប់ជំលួសនៅកម្ពុជា ។ ព្រះអង្គតែងតែប្រទានចំពោះឯកឧត្តមលោកហ៊ុន សែន និងគណប្រតិភូនៃរដ្ឋកម្ពុជាក្រាបថ្វាយបង្គំគាល់ជាបន្តបន្ទាប់នៅប្រទេសបារាំង ៖

- ពីថ្ងៃទី២ខែធ្នូឆ្នាំ១៩៨៧ចំនួយជាលើកទី១នៅ FERE-EN-TARDENOIS ។
- ពីថ្ងៃទី២០-២១ខែមករាឆ្នាំ១៩៨៨ជំនួយជាលើកទី២SAINL GRMAIN-EN-LAYE ។

នៅថ្ងៃទី២៤ខែមករាឆ្នាំ១៩៩១ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុបានទទួលពីមេដឹកនាំនៃកម្ពុជាទាំងបួនភាគីដើម្បីប្រកាសជាឱឡារិកនៅក្រុមព្រឹក្សាជាតិជាន់ខ្ពស់ហើយទទួលស្គាល់ការបញ្ឈប់ជាបណ្តោះអាសន្ននូវការបាញ់គ្នានៅក្នុងប្រទេសកម្ពុជាទាំងមូលនិងបញ្ឈប់ការផ្តល់ជំនួយយោធាអាវុធ... ពីប្រទេសដទៃដល់កងទ័ពកម្ពុជាទាំងបួន ។ ទីក្រុង

ភ្នំពេញត្រូវបានជ្រើសដោយក្រុមព្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា (SNC) ក្រោមព្រះរាជធិបតីដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ជាទីស្នាក់ផ្លូវការអចិន្ត្រៃ និងលេខាធិការស្ថានរបស់ក្រុមព្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា(SNC) ។

នៅថ្ងៃទី៧ខែកក្កដាឆ្នាំ១៩៩១ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុព្រះបានយាងចាក់ចេញពីប្រធាននៃកម្ពុជាប្រជាធិបតេយ្យនិងចលនាតស៊ូជាតិកម្ពុជា (CNR) ដើម្បីដាក់ព្រះកាយព្រះអង្គនៅពីលើភាគីនិងទស្សននយោបាយកម្ពុជានានា ។ ព្រះអង្គត្រូវបានសមាជិកទាំង១១នៃក្រុមព្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា(CNC) ជ្រើសតាំងជាឯកច្ឆ័នជាប្រធាន “អព្យាក្រឹត” នៃក្រុមព្រឹក្សានេះ ។

នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ នៅទីក្រុងបារីស ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុព្រះអង្គបានឡាយ

ព្រះហស្តលេខា "លើកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៃដំណោះស្រាយកម្ពុជា" ជាមួយសមាជិកនៃក្រុមព្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា១១រូបទៀតជាមួយតំណាងរដ្ឋាភិបាល១៨ប្រទេសនិងជាមួយលោកអគ្គលេខាធិការនៃអង្គាសហប្រជាជាតិ ។

នៅថ្ងៃទី១៤ខែវិច្ឆិកាឆ្នាំ១៩៩១ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុយាងនិវត្តមកកាន់រាជធានីភ្នំពេញវិញប្រកបដោយជោគជ័យនិងសុវត្ថិភាព ។ ក្រោយពីមាតុភូមិនិវត្តរបស់ព្រះអង្គ រដ្ឋាភិបាលនៃកម្ពុជាដែលមានឯកឧត្តមលោកហ៊ុន សែនជានិយករដ្ឋមន្ត្រីនិងឯកឧត្តមលោកជា ស៊ីមជាប្រធានគណបក្សប្រជាជនកម្ពុជា គណបក្សហ៊ុនសិនប៉ិចដែលមានព្រះអង្គម្ចាស់នរោត្តមរណឫទ្ធិ ជាប្រធានគណបក្សគណបក្សប្រជាធិបតេយ្យសេរីនិយម ពុទ្ធសាសនាដែលមានសម្តេចបវរសេដ្ឋាសឺនសានជាប្រធានគណបក្សនិងភាគីកម្ពុ-

ជាប្រជាធិបតេយ្យដែលមានលោកខៀវ សំផនជាប្រធាន បានប្រកាសជាបន្តបន្ទាប់ជាផ្លូវការនិងលាយល័ក្ខអក្សរថា ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុនៅតែជាប្រមុខរដ្ឋពេញលក្ខណៈនៃប្រទេសកម្ពុជាទាំងមូល ។ម្យ៉ាងទៀតព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ជាផ្លូវការនៅតែរក្សាទុកតួនាទីជាព្រះប្រមុខរដ្ឋរហូតដល់មានការបោះឆ្នោតនៅកម្ពុជាឆ្នាំ១៩៩៣ ។

នៅថ្ងៃទី២៤ខែកញ្ញា ឆ្នាំ១៩៩៣ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុបានឡាយព្រះហស្ថលេខាលើព្រះរាជក្រមប្រកាសឲ្យប្រើប្រាស់ជាផ្លូវការនៅរដ្ឋធម្មនុញ្ញថ្មីនៃព្រះរាជាណាចក្រកម្ពុជា ដែលសភាធម្មានុញ្ញកម្ពុជាបានអនុម័តិសម្រាប់ប្រគេនព្រះសង្ឃនិងជួយប្រជារាស្រ្ត ។ ព្រះអង្គបានប្រោសព្រះរាជទាននិងបន្តនូវការប្រោសព្រះរាជទាន(រៀង

រាល់សប្តាហ៍) ព្រះរាជអំណោយដល់ប្រជារាស្ត្រទីទល់ក្រនិងជីវភាពខ្វះខាតខ្លាំង ។

ព្រះរាជសកម្មភាពដ៏ថ្លៃថ្លាខាងលើនេះ បានបង្ហាញឲ្យឃើញនូវសច្ចធម៌នៃទស្សពិធរាជធម៌របស់ព្រះករុណាជាអង្គម្ចាស់ជីវិតដំកល់លើត្បូងជាទីសក្ការៈ ដែលព្រះអង្គបាននិងកំពង់ប្រោសព្រះរាជទានដល់ ប្រជារាស្ត្រកម្ពុជាដោយមិនប្រកាន់ជាតិ ជំនឿសាសនា ពណ៌សម្បុរសឡើយ ។ ដោយសាសច្ចភាពនេះហើយ ទើបប្រជារាស្ត្រកម្ពុជាទូទាំងប្រទេសបានគាំទ្រដោយឥតសំចៃថ្វាយព្រះអង្គ ចំពោះការយាងគ្រងរាជសម្បត្តិសាជាថ្មីនៅឆ្នាំ១៩៩៣ហើយ ដែលកំពង់ធ្លាប់មាននៅក្នុងប្រវត្តសាស្ត្រពិភពលោកកន្លងមក ។

## F <u>អាវសាន</u>

ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ទ្រង់យាងចូលទីវង្គត់នាថ្ងៃទី១៥រោច ខែភទ្របទឆ្នាំរោង ចត្វាស័ក ពុទ្ធស័ករាជ ២៥៥៦ ត្រូវនិងថ្ងៃទី១៥ខែតុលាឆ្នាំ២០១២ វេលាម៉ោង១និង២០នាទីម៉ោងនៅរាជធានីភ្នំពេញ នាមន្ទីពេទ្យទីក្រុងប៉េកាំងប្រទេសចិនដោយព្រះរាជពាធក្នុងព្រះជន្មាយុ៩០ វស្សា ៕



ព្រះចៅ ក្រុង កម្ពុជា